ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១៦ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២៥-៤-១៩៩៦	អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពីការបង្កើតទិវាបរិស្ថានជាតិ	
២៥-៤-១៩៩៦	អនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការបង្រួមកងពលធំថ្មើរជើងលេខ ២ និងកងពលធំថ្មើរជើងលេខ ១៤ ជាកងពលធំតែមួយ	៦៨២
២៥-៤-១៩៩៦	អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ	៦៨៤
២៥-៤-១៩៩៦	អនុក្រឹត្យលេខ១៨ អនក្រ.បក ស្តីពីការបង្កើតនីតិកម្មនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន	៦៨៧
២៥-៤-១៩៩៦	អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន	៦៩១
៣០-៤-១៩៩៦	អនុក្រឹត្យលេខ ២០ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន	៦៩៥
៣០-៤-១៩៩៦	អនុក្រឹត្យលេខ ២១ អនក្រ.បក ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា	៧០៧
៣០-៤-១៩៩៦	អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការចំរុះជំរុញការអភិវឌ្ឍន៍ទីក្រុងព្រះសីហនុ	៧០៨
២៤-៤-១៩៩៦	អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន	៧១១
២៧-៤-១៩៩៦	អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧១៣
២៧-៤-១៩៩៦	អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧១៤

៣០-៤-១៩៩៦ អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧១៥
៣០-៤-១៩៩៦ អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧១៦

២ - សេចក្ដីសំរេច

៣០-៤-១៩៩៦ សេចក្ដីសំរេចលេខ ១៣ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងតំបន់ប៉ៃលិន ៧១៧

II - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៦-៤-១៩៩៦ ប្រកាសលេខ ៣១៨ ឋព.ប្រក អនុញ្ញាតឱ្យលោក អ៊ុន សុផល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ចំនួន ០១ គ្រឿង ៧២២
២៦-៤-១៩៩៦ ប្រកាសលេខ ៣១៩ ឋព.ប្រក អនុញ្ញាតឱ្យលោក ហុង ឈីវគង់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ចំនួន ០១ គ្រឿង ៧២៣

២ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

២៤-៤-១៩៩៦ ប្រកាសលេខ ០៩៨/៩៦ ពម.ប្រក អនុញ្ញាតជូនលោក ញ៉ៀម វ៉ាលី បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « រណសិរ្ស ២ ធ្នូ » ៧២៤
២៤-៤-១៩៩៦ ប្រកាសលេខ ០៩៩/៩៦ ពម.ប្រក អនុញ្ញាតឱ្យទស្សនាវដ្ដីឈ្មោះ « ព្រឹត្តិបត្ររាជធានីភ្នំពេញ » បន្តចេញផ្សាយ ៧២៥
២៤-៤-១៩៩៦ ប្រកាសលេខ ១០០/៩៦ ពម.ប្រក អនុញ្ញាតឱ្យទស្សនាវដ្ដីឈ្មោះ « សម្លេងសហគមន៍ » បោះពុម្ពចែកផ្សាយ ៧២៧

ឥ

២៨-៤-១៩៩៦ ប្រកាសលេខ ១០១/៩៦ ពម.ប្រក អនុញ្ញាតឱ្យទស្សនាវដ្តីឈ្មោះ (THE CAMBODIAN SCENE) បោះពុម្ពចែកផ្សាយ ៧២៨

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

២៧-៤-១៩៩៦ ប្រកាសលេខ ៣៧១ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ពាមរាំង ទៅជា « អនុវិទ្យាល័យ ម្ចាស់ក្សត្រីយ៍ម៉ារីរណឫទ្ធិ » ស្ថិតនៅក្នុង ស្រុកលើកដែក ខេត្តកណ្តាល ៧៣០

២៧-៤-១៩៩៦ ប្រកាសលេខ ៣៧២ អយក.ប្រក ស្តីពីការបើក « អនុវិទ្យាល័យ បានយ » ក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ៧៣២

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៥ អនក្រ.បក

ស្តីពីការបង្កើតទិវាបរិស្ថានជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

សំរេច

ប្រការ ១ : កំណត់យកថ្ងៃ ០៥ ខែ មិថុនា រៀងរាល់ឆ្នាំ ដែលជាទិវាបរិស្ថានពិភពលោកធ្វើជាទិវាបរិស្ថានជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » គ្រប់ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត–ក្រុង ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវបំផុសអប់រំជូនមន្ត្រីរាជការ កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជារាស្ត្រ អំពីនយោបាយបរិស្ថានជាតិ គោលការណ៍យុទ្ធសាស្ត្រច្បាប់ បទបញ្ញត្តិនានា ស្តីអំពីការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាន ។

ប្រការ ៣ : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » គ្រប់ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត-ក្រុង ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវបំផុសចលនាឱ្យមន្ត្រីរាជការ កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃប្រជារាស្ត្រ ដាដើមឈើ និងចលនាការពារព្រៃឈើក្នុង បុព្វហេតុធ្វើអោយព្រះរាជាណាចក្រកម្ពុជាបៃតងជានិច្ចនិរន្តរ៍ ។

ប្រការ ៤ : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » ក្រសួងបរិស្ថានត្រូវធ្វើរបាយការណ៍ជាសាធារណៈចំពោះមុខរាជរដ្ឋាភិបាល ពីការបូកសរុបលទ្ធផលក្នុងកិច្ចការពារបរិស្ថាន ។

ប្រការ ៥ : ក្រសួងបរិស្ថានត្រូវសហការជាមួយគណៈកម្មាធិការបុណ្យជាតិ ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត-ក្រុង អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជន សមាគមនានា ដើម្បីចាត់ចែងរៀបចំទិវាបរិស្ថានជាតិ «០៥ មិថុនា » របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការបុណ្យជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៦ អនក្រ.បក

ស្តីពីការបញ្ចូលកងពលធំថ្មើរជើងលេខ ២ និង កងពលធំថ្មើរជើងលេខ ១៤ ជាកងពលធំតែមួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុង កម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជ រដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រសួងការពារ ជាតិ និង អគ្គសេនាធិការដ្ឋាន នៃកងទ័ពជាតិកម្ពុជា
- ផ្អែកតាមផែនការកសាងកំលាំងទ័ពចាប់ពីឆ្នាំ ១៩៩៥ រហូតដល់ ឆ្នាំ ១៩៩៧ លេខ ២២ ផ.ក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥
- ផ្អែកតាមសំណើសហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ នៃកងយោធ ពលខេមរភូមិន្ទ .

សំរេច

មាត្រា ១ : ត្រូវបានបង្រួមកងពលធំថ្មើរជើងលេខ ២ និងកងពលធំថ្មើរជើងលេខ ១៤ ជាកងពលធំតែមួយមានឈ្មោះថា កងពលធំថ្មើរជើងលេខ ២ ។

មាត្រា ២ : របនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់ កងពលធំថ្មើរជើងលេខ ២ អាស្រ័យដោយក្រសួងការពារជាតិ និង អគ្គសេនាធិការជាអ្នកកំណត់ ។

មាត្រា ៣ : ប្រគល់ជូនអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ចនិង ពេលវេលាជាក់ស្ដែងក្នុងការបង្រួមកងឯកភាពខាងលើ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយ .

ព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឬទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧ អនក្រ.បក

ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់

កងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ. ចុះថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋ មន្ត្រីនៃរដ្ឋកម្ពុជា ស្តីពីការកែលំអបៀវត្សរបស់កងទ័ព
- តាមសំណើរបស់ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : អនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធបៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ ទៅតាមឋានន្តរសក្តិចែកចេញជា ២០ ថ្នាក់ ដូចខាងក្រោម :

ល.រ	ឋានន្តរសក្តិ	ការបៀវត្ស
១	នាយឧត្តមសេនីយ៍	៧៤.៥០០៛
២	ឧត្តមសេនីយ៍ឯក	៧២.៥០០៛
៣	ឧត្តមសេនីយ៍ទោ	៧០.៥០០៛
៤	ឧត្តមសេនីយ៍ត្រី	៦៨.៥០០៛
៥	វរសេនីយ៍ឯក	៦៤.៥០០៛
៦	វរសេនីយ៍ទោ	៥៨.៥០០៛
៧	វរសេនីយ៍ត្រី	៥៤.៥០០៛
៨	អនុសេនីយ៍ឯក	៤៤.៤០០៛
៩	អនុសេនីយ៍ទោ	៤០.៤០០៛
១០	អនុសេនីយ៍ត្រី	៣៦.៤០០៛
១១	នាយចំណង់	៣២.៤០០៛
១២	ព្រិន្ទបាលឯក	២៨.៤០០៛
១៣	ព្រិន្ទបាលទោ	២៧.៤០០៛
១៤	ពលបាលឯក	២៦.៤០០៛
១៥	ពលបាលទោ	២៥.៤០០៛
១៦	ពលបាលត្រី	២៤.៥០០៛
១៧	នាយឯក	២៣.៤០០៛
១៨	នាយទោ	២៣.០០០៛
១៩	ពលឯក	២២.៥០០៛
២០	ពលទោ	២២.០០០៛

មាត្រា ២ : ប្រាក់ម្ហូបរបស់កងយោធពលខេមរភូមិន្ទ គឺជាប្រាក់បំណាច់ដោយឡែកសំរាប់ទិញម្ហូបអាហារនៅទីផ្សារអោយបានស្មើនិងគីរិតកំដៅ ២.៩៦៦កាឡូរី ។ ជាបណ្តោះអាសន្នផ្តល់ជារបបម្នាក់៩០០៛ (ប្រាំបួនរយរៀល មួយ ថ្ងៃដោយមិនគិតថ្លៃអង្ករ ០,៧៥ គីឡូក្រាម ម្នាក់មួយថ្ងៃដែលត្រូវផ្តល់ដោយឡែក ។

- ចំពោះប្រាក់អាហាររបស់កងយោធពលជាប្រភេទទ័ពជំនាញ ក្រសួងការពារជាតិត្រូវពិចារណាកំណត់ដោយឡែក ។

មាត្រា ៣ : ប្រាក់បំណាច់តំបន់ដាច់ស្រយាលត្រូវបើកផ្តល់ ១.៥០០៛ ម្នាក់១ខែ ចំពោះកងយោធពលខេមរភូមិន្ទ ដែលឈរជើងក្នុងភូមិសាស្ត្រត្រូវផ្តល់របប ដូចបុគ្គលិករដ្ឋដែរ ។

មាត្រា ៤ : ប្រាក់បំណាច់មុខងាររបស់កងយោធពលខេមរភូមិន្ទ ដែលធ្វើការក្នុងក្របខ័ណ្ឌជំនាញ ត្រូវទទួលរបបដូចខាងក្រោម :

១–អ្នកបើកបររថយន្តពាសដែក ម្នាក់ក្នុង ១ ខែ ១.៥០០៛
២–អាកាសយានិក ម្នាក់ក្នុង ១ ខែ ១.៣០០៛
៣–កងទ័ពជើងទឹក ម្នាក់ក្នុង ១ ខែ ១.១០០៛
៤–អ្នកបើកបររថក្រោះ ម្នាក់ក្នុង ១ ខែ ១.០០០៛
៥–កងទ័ពជាង ម្នាក់ក្នុង ១ ខែ ៩០០៛

មាត្រា ៥ : ចំពោះបុគ្គលិកដែលធ្វើការក្នុងក្របខ័ណ្ឌជាកម្មករក្រសួងការពារជាតិ ត្រូវផ្អែកលើសេចក្តីត្រូវការនិង សមត្ថកិច្ចជំនាញ ដើម្បីផ្តល់បៀវត្សតាមកាំ ប្រភេទដូចក្របខ័ណ្ឌកម្មកររដ្ឋក្នុងតារាងខាងក្រោម :

ប្រភេទ. កាំ	១	២	៣	៤	៥	៦
គ១	២៦.៤០០៛	២៨.៦០០៛	៣១.៤០០៛	៣៤.៣០០៛	៣៧.១០០៛	៤០.០០០៛
គ២	២៤.០០០៛	២៦.៤០០៛	២៩.៤០០៛	៣២.៥០០៛	៣៥.៥០០៛	៣៨.៥០០៛
គ៣	២១.៦០០៛	២៣.៧០០៛	២៥.៩០០៛	២៨.២០០៛	៣០.៤០០៛	៣៣.២០០៛
គ៤	១៥.៨០០៛	១៧.២០០៛	១៩.២០០៛	២១.០០០៛	២៣.០០០៛	២៥.២០០៛

មាត្រា ៦ : ប្រាក់បំណាច់មានលក្ខណៈជាគ្រួសារ

– កងយោធពលម្នាក់ ត្រូវបានផ្តល់របបប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ ៣.០០០៛ មួយខែ
– កូនកងយោធពល ត្រូវបានផ្តល់របបប្រាក់បំណាច់ឧបត្ថម្ភ ២.៥០០៛ ក្នុងកូនម្នាក់មួយខែ

មាត្រា ៧ : ក្រសួងការពារជាតិ ត្រូវបើករបបឧបត្ថម្ភដល់កងជីវពលដូចខាងក្រោម :

១–កងជីវពលការពារ និង ប្រតិបត្តិការផ្តល់របបម្ហូបប្រចាំថ្ងៃដូចកងយោធពល និង ផ្តល់ជាប្រាក់សំរាប់ទិញអង្ករដោយខ្លួនឯង ។

២–កងជីវពលឃុំ ផ្តល់ជាប្រាក់សំរាប់ទិញអង្ករ ១៨ គីឡូក្រាម និងអំបិល ២ គីឡូក្រាម ១ខែ ។

មាត្រា ៨ : បទបញ្ញត្តិទាំងឡាយណា ដែលមានន័យខ្ទឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បណ្តាក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៨ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្ម នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល ។

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ តាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤/៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលជំនួសអោយព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១៩ ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩៥ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែនចំណុះអោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **វ៉ា គឹមហុង**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ទទួលបន្ទុកកិច្ចការព្រំដែន	ប្រធាន
២-លោក **គួង ហ្លួរ**	ទីប្រឹក្សាច្បាប់របស់រាជរដ្ឋាភិបាល	ទីប្រឹក្សា
៣-ឯកឧត្តម **អ៊ុង ស៊ាន**	អនុរដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៤-ឧត្តមសេនីយ៍ត្រី **រស់ គឹមសាន**	ប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងការពារជាតិ	សមាជិក
៥-ឯកឧត្តម **សេង រ៉ុន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦-លោក **ម៉ៅ ឆាត់**	ទីប្រឹក្សាច្បាប់ក្រសួងយុត្តិធម៌	សមាជិក

៧-លោក **ឡុង ផុល** ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-លោក **ឡាយ ប៊ុនសុខ** ប្រធាននាយកដ្ឋានទាក់ទងអន្តរជាតិ នៃក្រសួងការពារជាតិ សមាជិក

៩-លោក **សុខ ជីវគុណា** ប្រធាននាយកដ្ឋានភូគព្ភសាស្ត្ររ៉ែនៃក្រសួងឧស្សាហកម្មរ៉ែនិងថាមពល
សមាជិក

១០-លោក **ប្រាក់ សារឿន** អនុប្រធាននាយកដ្ឋានជនបរទេសនៃអគ្គនាយកដ្ឋាននគរបាលជាតិនៃ ក្រសួងមហាផ្ទៃ សមាជិក

១១-លោក **ឃ[illegible] សាវ៉ាន** អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២-លោក **ហែម ក្រាញ់តូនី** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣-លោក **ស៊ា កុសល** ប្រធានការិយាល័យសន្ធិសញ្ញាក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
លេខាធិការ

១៤-លោក **កុលិន្ទ មុណី** មន្ត្រីនាយកដ្ឋានអាស៊ីទទួលបន្ទុកវៀតណាមនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុលេខាធិការ

១៥-លោក **ហូ ពេជ្រមោលី** មន្ត្រីនាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
អនុលេខាធិការ

១៦-លោក **អ៊ួន ណារុំ** មន្ត្រីនាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួង

ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
អនុលេខាធិការ

មាត្រា ២ : គណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ មានភារកិច្ច :

- ស្រាវជ្រាវ ដើម្បីរៀបចំឯកសារជាលក្ខណៈច្បាប់ (ទាំងព្រំដែនគោកទាំងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង) សំរាប់យកទៅតំកល់នៅអង្គការសហប្រជាជាតិ និងធ្វើជាមូលដ្ឋានបង្អែកសំរាប់ពិភាក្សាជាមួយប្រទេសជិតខាង ។
- ធ្វើការចរចាជាមួយប្រទេសជិតខាង ក្នុងការតំណាត់ជ្រើសរើសយកផែនទីសំរាប់ធ្វើការវាស់វែង ខ្សែបន្ទាត់ព្រំដែន ។
- ធ្វើរបាយការណ៍ ព័ស្តកម្មភាពការងាររបស់ខ្លួន ទៅអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំ ដែន ។

មាត្រា ៣ : គណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ មានលេខាធិការដ្ឋានសំរាប់ជំនួយការរដ្ឋបាលនិងសំរបសំរួលការងារបច្ចេកទេសដែលមានទីស្នាក់ការនៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលមានឯកឧត្តម អ៊ុំ ស៊ាន ជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការនីតិកម្ម ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ ជាផ្នែកមួយនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានទីតាំងនៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខានៃលេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ ត្រូវជាសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាក់ព័ន្ធ ព្រមទាំង ឯកឧត្តម អស់លោក សាមីជន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៥ : អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស

ស្តីពីកិច្ចការព្រំដែន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាល ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលជំនួសអោយព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១៩ ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩៥ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅ :

១–សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ប្រធាន

២–ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ចំរើន ជាតិ** មេបញ្ជាការកងការពារព្រំដែន នៃក្រសួងការពារជាតិ អនុប្រធាន

៣–ឧត្តមសេនីយ៍ត្រី **រស់គីមសាន** នាយក នាយកដ្ឋានភូមិសាស្ត្រនៃក្រសួងការពារជាតិ សមាជិក

៤–ឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្ត កំពង់ចាម សមាជិក

៥–ឯកឧត្តម **ឡូយ សុផាត** អភិបាលខេត្ត ស្វាយរៀង សមាជិក

៦–ឯកឧត្តម **ខេព នន្ទី** អភិបាលខេត្ត ព្រៃវែង សមាជិក

៧–ឯកឧត្តម **ស៊ូ តិរិទ្ធ** អភិបាលខេត្ត តាកែវ សមាជិក

៨–ឯកឧត្តម **រុង ផ្លាមកេសន** អភិបាលខេត្ត កោះកុង សមាជិក

៩–ឯកឧត្តម **អ៊ុង សាមី** អភិបាលខេត្ត បាត់ដំបង សមាជិក

១០–ឯកឧត្តម **ដួង ខែម** អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក

១១–ឯកឧត្តម **ទន់ ចាយ** អភិបាលខេត្ត សៀមរាប សមាជិក

១២–ឯកឧត្តម **ឈឺ ស៊ូ** អភិបាលខេត្ត ស្ទឹងត្រែង សមាជិក

១៣–ឯកឧត្ដម **កែប ជុតិមា** អភិបាលខេត្ត រតនគីរី សមាជិក

១៤–ឯកឧត្ដម **ឌូ គៀង** អភិបាលខេត្ត ក្រចេះ សមាជិក

១៥–ឯកឧត្ដម **ឌុំ ឈឿង** អភិបាលខេត្ត មណ្ឌលគីរី សមាជិក

១៦–ឯកឧត្ដម **គុណា គឹមសេង** អភិបាលខេត្ត កំពត សមាជិក

១៧–ឯកឧត្ដម **មាន សារិន** អភិបាលខេត្ត ព្រះវិហារ សមាជិក

១៨–ឯកឧត្ដម **ចក់ សារិក** អភិបាលខេត្ត កណ្ដាល សមាជិក

១៩–ឯកឧត្ដម **រស់ ស្រេង** អភិបាលខេត្ត ពោធិសាត់ សមាជិក

២០–លោក **អ៊ាត លីហេង** អនុប្រធាននាយកដ្ឋានអាស៊ីនិង អូស្ត្រាលី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ សមាជិក

២១–លោក **ហួន សាវ៉ាង** អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

២២–លោក **លឹម វ៉ាន់** ប្រធានស្ដីទីនាយកដ្ឋានសុរិយោដី នៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

២៣–លោក **ម៉ែន អ៊ាន** ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

២៤–លោក **ជេត ខេមរា** មន្ត្រីនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និង រដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ សមាជិក

២៥–លោក **កុលិន្ទ មុណី** មន្ត្រីនាយកដ្ឋានអាស៊ីទទួលបន្ទុក វៀតណាម នៃក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ សមាជិក

២៦–លោក **ឌី សុផាន** អនុប្រធានទី ១ នាយកដ្ឋានកិច្ចការ នយោបាយនៃក្រសួងមហាផ្ទៃ លេខាធិការ

មាត្រា ២ : គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះ មានខ្សែបណ្តាញជាភ្នាក់ងារកិច្ចការព្រំដែន រហូតដល់ខេត្ត និង ស្រុក ។

មាត្រា ៣ : គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន មានភារកិច្ចត្រួតពិនិត្យការពារបន្ទាត់ព្រំដែនក្នុងរយៈរង់ចាំការដោះស្រាយ ធ្វើអន្តរាគមន៍ដោះស្រាយ ចំពោះបាតុភាព ឬទំនាស់ព្រំដែនជាមួយខេត្តជាប់ព្រំដែនរបស់ប្រទេសជិតខាង និងចុះធ្វើការវាស់វែងបោះគោលបន្ទាត់ព្រំដែន តាមស្មារតីនៃលទ្ធផលដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។ ចូលរួមជាមួយគណៈកម្មាធិការនីតិកម្ម ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមការចាំបាច់ ។

មាត្រា ៤ : គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន មានលេខាធិការដ្ឋានជាជំនួយការរដ្ឋបាល និងសំរបសំរួលការងារដែលមានទីស្នាក់ការនៅក្រសួងមហាផ្ទៃ ។ គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះ ជាផ្នែកមួយរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមានទីតាំងនៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខានៃលេខាធិការដ្ឋាននៃគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះត្រូវជាសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការ ព្រំដែន ។ ក្នុងករណីចាំបាច់គណៈកម្មាធិការបច្ចេកទេសនេះអាចបង្កើត ឬរៀបចំអនុគណៈកម្មការផ្សេង ៗ ដើម្បីសំរបសំរួលឬបំពេញភារកិច្ចរបស់គណៈកម្មាធិការបច្ចេកទេសនេះអោយមានប្រសិទ្ធភាព ។

មាត្រា ៥ : សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមអភិបាលខេត្តជាប់ព្រំដែន និងសាមីជនដែលមានឈ្មោះចែងក្នុងមាត្រា ១ ព្រមទាំងក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួល

អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២០ អនក្រ.បក
ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់
ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- តាមតម្រូវការនៃការរៀបចំគ្រប់គ្រង និង ការប្រព្រឹត្តទៅរបស់ក្រសួង និង

រដ្ឋលេខាធិការដ្ឋាន

_ តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អង្គភាពរដ្ឋបាលរបស់រដ្ឋ ត្រូវប្រមូលផ្តុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។ ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ ត្រូវដាក់ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូប ។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពនានាចំណុះក្រសួង ឬរដ្ឋលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ ។ ពុំអាចដាក់អង្គភាពថ្នាក់កណ្តាលណាមួយអោយស្ថិតនៅក្រោមឋានានុក្រមនៃក្រសួង ឬ រដ្ឋលេខាធិការដ្ឋានពីរ ឬ ច្រើនផ្សេងពីគ្នាបានឡើយ ។ ផ្ទុយទៅវិញ ក្រៅពីអង្គភាពដែលចំណុះទីស្តីការគណៈរដ្ឋមន្ត្រី គ្មានអង្គភាពរដ្ឋបាលណាមួយ ដែលមិនស្ថិតនៅក្រោមឋានានុក្រមនៃ ក្រសួង ឬរដ្ឋលេខាធិការដ្ឋានណាមួយឡើយ លើកលែងតែអង្គភាពឬអាជ្ញាធរ ដែលមានស្វ័យភាព ។

មាត្រា ២ : អនុក្រឹត្យនេះមិនគ្របដណ្តប់ទៅលើការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិឡើយ ។

ជំពូកទី ២

ការរៀបចំរចនាសម្ព័ន្ធ

មាត្រា ៣ : ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ រួមមាន ÷

- អង្គភាពកណ្ដាលមួយ ឬច្រើនចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន
- អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន
- គ្រឹះស្ថានសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យរបស់រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័ន

មាត្រា ៤ : អង្គភាពកណ្ដាលចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ អាចមាន ÷

- អគ្គលេខាធិការដ្ឋានមួយ ក្នុងករណីពិសេស
- អគ្គនាយកដ្ឋានមួយ ឬច្រើន ដែលបែងចែកជានាយកដ្ឋាន
- អគ្គាធិការដ្ឋានមួយ ឬ អធិការដ្ឋានមួយ
- អគ្គនាយកដ្ឋាន ឬ នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅមួយ
- នាយកដ្ឋានជំនាញមួយចំនួន

មាត្រា ៥ : អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន រួមអាចមាន ÷

ក—ថ្នាក់ខេត្ត - ក្រុង

- មន្ទីរជំនាញដឹកនាំដោយប្រធានមន្ទីរ
- មន្ទីរជំនាញនីមួយៗ ចែកចេញជាការិយាល័យ ។

ក្រៅពីការិយាល័យមន្ទីរជំនាញនីមួយៗ អាចមានអង្គភាពចំណុះមួយចំនួន។

ខ—ថ្នាក់ស្រុក - ខណ្ឌ

- ការិយាល័យមួយដែលចែកចេញជាផ្នែកផ្សេងៗ

ការរៀបចំនិងការប្រព្រឹត្តិ ទៅ នៃអង្គភាពមូលដ្ឋាន (ខាងក្រៅ) ទាំងនេះ នឹងត្រូវកំណត់ដោយ អនុក្រឹត្យមួយផ្សេងទៀត ។

ជំពូកទី ៣

អំពីអគ្គនាយកដ្ឋាន

មាត្រា ៦ : ប្រព័ន្ធរដ្ឋបាលនៃក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយ ៗ ត្រូវរៀបចំអោយមានជាអគ្គនាយកដ្ឋាន ដែលបែងចែកជានាយកដ្ឋាន ។ នាយកដ្ឋាននីមួយៗបែងចែកជាការិយាល័យ ។

ប្រព័ន្ធរដ្ឋបាលនៃក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ដូចបានរៀបរាប់រួចមកហើយនេះ ត្រូវរៀបចំតាមអង្គការលេខតំរូ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ការបង្កើតអគ្គនាយកដ្ឋាន និង នាយកដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យដែលនឹងបញ្ជាក់អំពីភារកិច្ច និង ការរៀបចំរបស់អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ។ ចំណែកការបង្កើតការិយាល័យក្រសួង ឬ រដ្ឋលេខាធិការដ្ឋានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាមី ដែលនឹងបញ្ជាក់នូវភារកិច្ច នៃការិយាល័យនោះ ។

មាត្រា ៧ : អគ្គនាយកដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកមួយរូប ។ ក្នុងករណីចាំបាច់អាចមានអគ្គនាយករងជាជំនួយការ ។

នាយកដ្ឋានស្ថិតក្រោមការ គ្រប់គ្រងរបស់ប្រធាននាយកដ្ឋានមួយរូប ។ ក្នុងករណីពិសេស ប្រធាន នាយកដ្ឋានមួយអាចមានឋានៈ និងបុព្វសិទ្ធិជាអគ្គនាយក ។ ប្រធាន នាយកដ្ឋាន មានអនុប្រធាននាយកដ្ឋានមួយរូប ឬច្រើនរូបជាជំនួយការ ។ ការិយាល័យស្ថិតក្រោមការគ្រប់គ្រងរបស់នាយការិយាល័យមួយរូប ដែលមាននាយរងការិយាល័យជាជំនួយការ ។

អគ្គនាយក ប្រធាននាយកដ្ឋាន និង នាយការិយាល័យ ត្រូវទទួលខុសត្រូវចំពោះដំណើរការអង្គភាពរបស់ខ្លួន និងការអនុវត្តន៍ភារកិច្ចដែលថ្នាក់លើប្រគល់អោយ តាមដានកិច្ចអនុវត្តបទបញ្ជា និងការណែនាំរបស់ថ្នាក់លើក្នុងក្របខ័ណ្ឌច្បាប់ ។

មាត្រា ៨ : អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រមុខ រាជរដ្ឋាភិបាល ដោយយោងតាមសំណើរបស់ប្រធានស្ថាប័នសាមី ។

អគ្គនាយករងមានឋានៈសមមូលនិងប្រធាននាយកដ្ឋាន នឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។ ចាប់តាំងពីថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល រហូតដល់នាយការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់ប្រធានស្ថាប័ន។ មន្ត្រីខាងលើនេះត្រូវតែងតាំងក្នុងចំណោមមន្ត្រីរាជការដែលមានក្នុងក្របខ័ណ្ឌមុខងារសាធារណៈហើយត្រូវមានលក្ខណសម្បត្តិ គឺវិជ្ជា សមត្ថភាពជំនាញ អតីតភាព ព្រមទាំងឋានន្តរសក្តិស្របតាមលក្ខន្តិកៈដោយឡែកនៃអង្គមន្ត្រីនីមួយៗ ។

មាត្រា ៩ : អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ត្រូវទទួលបន្ទុកការងាររួម-រដ្ឋបាល បូកសរុប រាយការណ៍ ឯកសារ -បុគ្គលិក -ផែនការ - ហិរញ្ញវត្ថុ និង សំភារៈបរិក្ខារ ។

ជំពូកទី ៤

អំពីអគ្គាធិការដ្ឋាន ឬ អធិការដ្ឋាន

មាត្រា ១០ : អគ្គាធិការដ្ឋាន ឬ អធិការដ្ឋាន មានភារកិច្ចត្រួតពិនិត្យ ដើម្បីអោយអង្គភាពរដ្ឋបាលកណ្តាល អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬរដ្ឋលេខាធិការដ្ឋានមានដំណើរការល្អ ។ ក្នុងករណីនេះអគ្គាធិការដ្ឋាន ឬអធិការដ្ឋានមានភារកិច្ចត្រួតពិនិត្យដំណើរការរបស់អង្គភាព និងនាយកដ្ឋានទាំងនោះអោយស្របតាមគោលច្បាប់ ស្របតាមទិសដៅ និងបទបញ្ជារបស់ប្រធានស្ថាប័ន ។ អគ្គាធិការដ្ឋាន ឬអធិការដ្ឋាន រាយការណ៍អំពីបេសកកម្មរបស់ខ្លួនជូនប្រធានស្ថាប័ន ប៉ុន្តែពុំមានសិទ្ធិសំរេចជំនួសទេ ។

មាត្រា ១១ : អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប អាចមានអគ្គាធិការរងជាជំនួយការ យោលទៅតាមតម្រូវការ ។ អធិការដ្ឋានដឹកនាំដោយអធិការមួយរូបអាចមានអធិការរង ១ ឬ ២ រូប ជាជំនួយការ ។

មាត្រា ១២ : អគ្គាធិការមានឋានៈសមមូល និងអគ្គនាយក ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ដោយយោងសំណើប្រធានស្ថាប័នសាមី ក្នុងចំណោមអធិការរបស់ក្រសួងដែលមានគុណសម្បត្តិ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងកិច្ចការនេះ ។ រីឯអធិការមានឋានៈសមមូល និងប្រធាន នាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធានស្ថាប័នសាមី ក្នុងចំណោមមន្ត្រីរាជការនៃក្រសួង ដែលធ្លាប់បំរើការយ៉ាងតិច ៥ ឆ្នាំ ជា មន្ត្រីទទួលខុសត្រូវខ្ពស់ ឬធ្លាប់មានតួនាទីសំខាន់ ។

អគ្គាធិការរង និងអធិការមានឋានៈសមមូលនិងប្រធាននាយកដ្ឋាននឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។ អធិការរងមានឋានៈសមមូល និងអនុប្រធាននាយកដ្ឋាន ដែលនឹងត្រូវតែងតាំងដោយប្រកាសរបស់ប្រធានស្ថាប័នសាមី ។

មាត្រា ១៣ : អគ្គនាយកដ្ឋាន - អគ្គលេខាធិការដ្ឋាន - អគ្គាធិការដ្ឋាន - នាយកដ្ឋាន អធិការដ្ឋាន និងការិយាល័យជាអង្គភាពថានានិរន្តរភាព នៃប្រព័ន្ធរដ្ឋបាលរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូកទី ៥

អំពីការត្រួតពិនិត្យហិរញ្ញកិច្ច

មាត្រា ១៤ : ក្រសួងឬរដ្ឋលេខាធិការដ្ឋាននីមួយៗ មានអង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ ។ អភិបាលត្រួតពិនិត្យហិរញ្ញវត្ថុមួយ ឬ ពីរនាក់ ជ្រើសរើសក្នុងចំណោមមន្ត្រីរាជការមានជំនាញ និង បទពិសោធន៍គ្រប់គ្រាន់ តែងតាំងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើការអមក្រសួង និង រដ្ឋលេខាធិ... ន ។

មាត្រា ១៥ : ការត្រួតពិនិត្យហិរញ្ញកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋទៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង ។ ក្នុងករណីនេះ អគ្គិចាលត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរាយការណ៍ភ្លាមនូវបាតុភាពទាំងឡាយ ដែលខ្លួនបាន ពិនិត្យឃើញជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលខ្លួននៅក្រោមឱវាទ និង ជូនរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ជាប្រធានស្ថាប័នសាមី ។

ជំពូកទី ៦

អំពីខុទ្ទកាល័យរបស់ប្រធានស្ថាប័ន

មាត្រា ១៦ : ខុទ្ទកាល័យក្រសួង ឬ រដ្ឋលេខាធិការដ្ឋានជាអង្គភាពដោយឡែក ដែលមានបេសកកម្មជាជំនួយរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្នុងឋានៈរបស់លោកជាអ្នកនយោបាយផ្នែកលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និងរដ្ឋសភាជាតិ ក៏ដូចជាក្នុងឋានៈលោកជាអ្នកដឹកនាំរដ្ឋបាល ក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ។

មាត្រា ១៧ : ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍ :

- រៀបរងទំនាក់ទំនងជាមួយ និង ខុទ្ទកាល័យរបស់រដ្ឋមន្ត្រីឯទៀត ព្រមទាំងទំនាក់ទំនង ជាមួយអ្នកតំណាងរាស្ត្រ និងប្រព័ន្ធឃោសនាទាំងឡាយ ។
- ផ្តល់យោបល់ជូនរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ចំពោះកិច្ចការទូទៅក្នុងក្រសួង និង ចំពោះសំណុំរឿងទាំងឡាយដែលប្រធានស្ថាប័នបានប្រគល់អោយពិនិត្យ ។ ភារកិច្ចផ្តល់យោបល់នេះមិនផ្តល់សិទ្ធិអោយខុទ្ទកាល័យបំពេញការងារជំនួសអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ឡើយ ។
- ចែកផ្សាយអំពីគោលដៅរបស់ប្រធានស្ថាប័ន ។
- រៀបចំកាលវិភាគរបស់រដ្ឋមន្ត្រី និងអង្គភាពចំណុះក្រសួង រួចតាមដានការ

អនុវត្តន៍ការងារទាំងនោះអោយស្របតាមគោលវិភាគដែលបានកំណត់ ។

- រៀបចំសម័យប្រជុំការងារក្នុងក្រសួងផ្ទាល់ ព្រមទាំងកិច្ចប្រជុំការងារអន្តរក្រសួង ។
- បញ្ជូនបទបញ្ជារដ្ឋមន្ត្រី ដល់អង្គភាពទាំងឡាយក្នុងក្រសួង តាមកិរិតដែលរដ្ឋមន្ត្រី ប្រធានស្ថាប័នប្រគល់សិទ្ធិអោយ ។
- តាមដាន និង សំរបសំរួលសកម្មភាពផ្សេងៗ ទាំងឡាយរបស់ក្រសួង ឬរដ្ឋលេខាធិការដ្ឋានដើម្បីសំរួលការងារ និងតាមដានការអនុវត្តន៍បញ្ជារបស់រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ។

មាត្រា ១៨ : សមាជិកខុទ្ទកាល័យ ត្រូវជ្រើសរើសដោយប្រធានស្ថាប័នផ្ទាល់តាមការយល់ឃើញនិងទំនុកទុកចិត្តរបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនោះ ហើយអាចបញ្ឈប់សមាជិកណាម្នាក់នៃខុទ្ទកាល័យនោះ បានគ្រប់ពេលវេលាដោយមិនចាំបាច់បញ្ជាក់ពីមូលហេតុអ្វីទាំងអស់ ។ សមាជិកខុទ្ទកាល័យត្រូវចាកចេញពីមុខតំណែងរបស់ខ្លួន ពេលមានការផ្លាស់ប្តូររដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលបានជ្រើសរើសខ្លួន វៀរលែងតែរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែលចូលកាន់តំណែងថ្មីបានឯកភាពចារក្សាទុកសមាជិកណាមួយ នៃអតីតខុទ្ទកាល័យ ។

មាត្រា ១៩ : មុខងារ នៃសមាជិកខុទ្ទកាល័យ ជាមុខងារសំរាប់តែមួយរយៈប៉ុណ្ណោះ ។ ហេតុនេះសមាជិកខុទ្ទកាល័យណា ដែលពីមុនគ្មានលក្ខណសម្បត្តិដើមជាមន្ត្រីក្របខ័ណ្ឌ ពុំអាចទាមទារលក្ខណសម្បត្តិនេះបានដោយយោលទៅលើការតែងតាំងខ្លួនជាសមាជិកខុទ្ទកាល័យនោះឡើយ ផ្ទុយទៅវិញនៅពេលដែលខ្លួនបានចាកចេញពីមុខតំណែងដើម ដើម្បីចូលមកបំរើការខុទ្ទកាល័យ សមាជិកខុទ្ទកាល័យដែលមានលក្ខណសម្បត្តិជាមន្ត្រីក្របខ័ណ្ឌ រួចមកហើយ ត្រូវរក្សាទុកនូវលក្ខណសម្បត្តិនេះ ព្រមទាំងអតីតភាពរបស់ខ្លួនក្នុងក្រសួង ឬ រដ្ឋលេខាធិការដ្ឋានដើម ។

មាត្រា ២០ : ខុទ្ទកាល័យដឹកនាំដោយនាយកខុទ្ទកាល័យមួយរូប ដែលត្រូវតែងតាំងដោយប្រកាស ។

នាយកខុទ្ទកាល័យមាននាយខុទ្ទកាល័យម្នាក់ ដែលត្រូវតែងតាំងដោយប្រកាសជា អ្នកជំនួយការដែលមានភារកិច្ចជាអាទិ រ៉ាប់រងការងារទាក់ទងពិធីការនិង ទំនាក់ទំនងជាមួយសាធារណជន ។

មាត្រា ២១ : ក្រៅពីនាយកខុទ្ទកាល័យ និងនាយខុទ្ទកាល័យ ខុទ្ទកាល័យអាចមានសមាជិក÷ ទីប្រឹក្សាបច្ចេកទេស អនុពន្ធសភា អនុពន្ធសារពតិមាន និងលេខាធិការផ្ទាល់ដែលតែងតាំងដោយប្រកាស ។ មន្ត្រីទាំងនេះមិនត្រូវមានចំនួនលើសពី ៣ រូប ចំពោះទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ២ រូប ចំពោះរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន និង ១ រូប ចំពោះរដ្ឋលេខាធិការដែលពុំមែនជាប្រធានស្ថាប័ន ។ មន្ត្រីខុទ្ទកាល័យខាងលើនេះ ពិនិត្យលើសំណុំរឿងដែលនាយកខុទ្ទកាល័យប្រគល់អោយហើយជួយនាយកខុទ្ទកាល័យតាមសមត្ថភាពរបស់ខ្លួនម្នាក់ៗ ។ ការបែងចែកភារកិច្ចរបស់សមាជិកខុទ្ទកាល័យត្រូវកំណត់ដោយប្រកាសរបស់ ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។

មាត្រា ២២ : បន្ថែមលើបុគ្គលិករាជការ ដែលបានកំណត់ក្នុងមាត្រា ២១ ខាងលើ ប្រធានស្ថាប័ននីមួយៗ អាចមានបេសកជន ទីប្រឹក្សា និងជំនួយការដែលបំពេញបេសកកម្ម ក្នុងក្របខ័ណ្ឌ ខុទ្ទកាល័យ ដែលមានចំនួនសរុបមិនលើសពីបីរូប ហើយត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ២៣ : អង្គភាពបុគ្គលិកត្រូវផ្តល់បុគ្គលិកក្របខ័ណ្ឌរបស់ក្រសួង ឬរដ្ឋលេខាធិការដ្ឋានជូនខុទ្ទកាល័យរ៉ាប់រងលើកិច្ចការផ្នែកផ្គត់ផ្គង់ ដូចជាអ្នកបើកបរឬលេខាធិការការិយាល័យ ។ ល ។ មុខតំណែងរបស់ភ្នាក់ងារទាំងអស់នេះ ជាមុខតំណែងរដ្ឋបាលធម្មតាដែលពុំត្រូវមានការផ្លាស់ប្តូរជាស្វ័យប្រវត្តិ នៅពេលដែលមានការផ្លាស់ប្តូររដ្ឋមន្ត្រី ។

ជំពូកទី ៧

អវសានបញ្ញត្តិ

មាត្រា ២៤ : ក្រសួង និង រដ្ឋលេខាធិការដ្ឋានទាំងអស់ត្រូវតែរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ អោយស្របតាមបទបញ្ញត្តិនៃអនុក្រឹត្យនេះ ។

មាត្រា ២៥ : បទបញ្ញត្តិផ្ទុយទាំងឡាយណា ដែលមានឋានានុក្រមស្មើ ឬទាបជាងអនុក្រឹត្យ នេះត្រូវទុក ជានិរាករណ៍ ។

មាត្រា ២៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ ទាំងអស់មានបន្ទុករៀង ៗ ខ្លួនអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ឧបសម្ព័ន្ធ

គំរូទី ១

អង្គភាពលេខ ក្រសួង..........



ឧបសម្ព័ន្ធ

គំរូទី ១

អង្គការលេខ ក្រសួង.........



រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២១ អនក្រ.បក

ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍

របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាព្រះក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារចំនួន ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ និងត្រូវបានអនុញ្ញាតអោយឈប់សំរាកការងារចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ គឺថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

មាត្រា ២ : មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារអោយ បានទៀងទាត់ តាមរយៈពេលដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ និងធ្វើ ការក្នុងមួយថ្ងៃចំនួន ៨ ម៉ោង គឺ ÷

-ព្រឹកពីម៉ោង ៧ និង ០០ នាទី ដល់ម៉ោង ១១ និង ៣០ នាទី

-ល្ងាចពីម៉ោង ១៤ និង ០០ នាទី ដល់ម៉ោង ១៧ និង ៣០ នាទី

មាត្រា ៣ : រយៈពេលបំពេញការងារប្រចាំសប្តាហ៍របស់សាស្ត្រាចារ្យ គ្រូបង្រៀន បុគ្គលិកសិក្សាតាមគ្រឹះស្ថានសិក្សានានា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

មាត្រា ៤ : ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២២ អនក្រ.បក
ស្តីពីការបង្កើតគណៈកម្មការចំរុះជំរុញការ
អភិវឌ្ឍន៍ ទីក្រុងព្រះសីហនុ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៨៣ នស.រកត ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការចំរុះសំរាប់ជំរុញការអភិវឌ្ឍន៍ ទីក្រុងព្រះសីហនុដោយក្រុមហ៊ុន ARISTON SDN-BHD ដែលមានសមាសភាពដូចខាងក្រោម ÷

១- សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ ឬ តំណាង ជាសហប្រធាន

២- ឯកឧត្តម **សុខ អាន** និង ឯកឧត្តម **ម៉េង សរីទ្ធារ៉ា** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ឬតំណាង ជាសហអនុប្រធាន

៣-ឯកឧត្តម **អ៊ុង ភឿត** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ តំណាង ជាសមាជិក

៤-ឯកឧត្តម **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ជាសមាជិក

៥-ឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការរៀបចំដែនដី និងនគរូបនីយកម្ម ឬតំណាង ជាសមាជិក

៦-ឯកឧត្តម ពូ សុធីរៈ	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឬតំណាង ជាសមាជិក
៧-ឯកឧត្តម សូ ឃុន	រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ឬតំណាង ជាសមាជិក
៨-តំណាងក្រសួងទេសចរណ៍	ជាសមាជិក
៩-ឯកឧត្តម ម៉ុក សំឯល	អនុរដ្ឋលេខាធិការអាជ្ញាធរអាកាសចរណ៍ ស៊ីវិល ឬតំណាង ជាសមាជិក
១០-ឯកឧត្តម អ៊ិត វិជិត្រ	អគ្គលេខាធិការគណៈកម្មការជាតិវិនិយោគ ឬតំណាង ជាសមាជិក
១១-ឯកឧត្តម ម៉ម សុផាណា	អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន ឬតំណាង ជាសមាជិក
១២-ឯកឧត្តម ជាំ សោភ័ណ	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ១ ឬតំណាង ជាសមាជិក
១៣-ឯកឧត្តម ឌីយ៉ាច	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ ឬតំណាង ជាសមាជិក
១៤-ឯកឧត្តម ថោ្វ ម៉ុនស្រ៊ុន	និងឯកឧត្តម យឹម ម៉ូរ អភិបាលរងទី ១ ឬតំណាងក្រុងព្រះសីហនុ ជាសមាជិក
១៥-តំណាងរបស់ក្រុមហ៊ុន ARISTON SDN-BHD	ជាសមាជិក

មាត្រា ២ : គណៈកម្មការនេះមានភារកិច្ច :

ទទួលបន្ទុកតាមដាន ជំរុញ និងដោះស្រាយលើកិច្ចអភិវឌ្ឍន៍ ក្រុងព្រះសីហនុ របស់ក្រុមហ៊ុនវិនិយោគ ARISTON SDN-BHD ដើម្បីបង្កលក្ខណៈងាយស្រួលអោយក្រុមហ៊ុន សំរេចបាននូវរាល់ភារកិច្ចអោយស្របទៅតាមកម្មវិធីការងារដែលមានចែងក្នុងកិច្ចសន្យារវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនកន្លងមក ។

មាត្រា ៣ : គណៈកម្មការនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ដើម្បីជួយការងារនិង មានសិទ្ធិ ប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សម្តេច ឯកឧត្តម អស់លោក ដូចមានឈ្មោះ ក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៦៩ អនក្រ.តត

ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការ បង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខងារ នាយទាហានជាន់ខ្ពស់ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមនេះ ។

១- លោកវរសេនីយឯក **ស្វាយ សខួន** មេបញ្ជាការរងកងពលធំលេខ ១៤ បច្ចុប្បន្នជា មេបញ្ជាការរងកងពលធំលេខ ២

២- លោកវរសេនីយ៍ឯក **អ៊ា សឿន** មេបញ្ជាការរងកងពលធំលេខ ២ ចាស់ បច្ចុប្បន្នជាមេបញ្ជាការរងកងពលធំលេខ ២

៣-លោកវរសេនីយឯក **យ៉ោក ចណ្ណាលុច្ស** មេបញ្ជាការរងកងពលធំលេខ ១៤ បច្ចុប្បន្នជា មេបញ្ជាការរងកងពលធំលេខ ២

៤-លោកវរសេនីយ៍ឯក **យឹម សាខន** មេបញ្ជាការរងកងពលធំលេខ ២ ចាស់ បច្ចុប្បន្នជាមេបញ្ជាការរងកងពលធំលេខ ២

៥-លោកវរសេនីយ៍ឯក **គល់ ទ័** នាយករសេនាធិការកងពលធំលេខ ២ ចាស់ បច្ចុប្បន្នជាមេបញ្ជាការរងកងពលធំលេខ ២

៦-លោកវរសេនីយឯក **ម៉ៃ ប៊ុនធឿន** នាយសេនាធិការរងកងពលធំលេខ ១៤ បច្ចុប្បន្នជានាយសេនាធិការកងពលធំលេខ ២

៧-លោកវរសេនីយឯក **យឹន យាន** មេបញ្ជាការរងកងពលធំលេខ ១៤ បច្ចុប្បន្នជានាយទាហានរង់ចាំបញ្ជាការដ្ឋានរដ្ឋបាល អ. ស. ធ.

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងអស់លោកត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៧០ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងសមាជិកក្រុមលេខាធិការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ ចំនួន៣រូប ដូចមានឈ្មោះខាងក្រោមអោយមានឋានៈស្មើប្រធាននាយកដ្ឋាន÷

១ – លោក **ខាំ យុតា**

២ – លោក **ហោ សារ៉ានី**

៣ – លោក **ហាក់ សុខហៃ**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនិងសាមីខ្លួន

ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៧១ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោកស្រី **ឡូ សុខា** ជាសមាជិកក្រុមលេខាធិការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការរដ្ឋនៃលេខាធិការដ្ឋានមុខងារសាធារណៈនិងសាមីខ្លួន

ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៧២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបំពេញបន្ថែមក្នុងតារាងបៀវត្សចំណាយកាំប្រាក់នូវបណ្ណាឋានៈថ្មីសមមូល និងកាំប្រាក់ឋានៈនាទីចាស់របស់មន្ត្រីរាជការស៊ីវិល ។
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : ត្រូវបានតែងតាំង លោក **គីម ម៉ុនថាន** ជំនួយការឯកឧត្តម ឧត្តមសេនីយ៍ទោ **គន់ គីម** បេសកជនពិសេសម្តេចនាយករដ្ឋមន្ត្រីទី ២

មានឋានៈស្មើ ប្រធាននាយកដ្ឋាន ៖

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមាន ចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកទអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៦

អនុក្រឹត្យលេខ ៧៣ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបំពេញបន្ថែមក្នុងតារាងបៀវត្សចំណាយកាំប្រាក់ នូវបណ្តាឋានៈថ្មីសមមូល និងកាំប្រាក់ឋានៈនាទីចាស់របស់មន្ត្រីរាជការស៊ីវិល
- ពិនិត្យសំណូមពរការងារចាំបាច់ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងអស់លោកដូចរាយឈ្មោះខាងក្រោម ជាជំនួយការទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ៖

- លោក **ម៉ុន ណារិទ្ធិ** ជំនួយការឯកឧត្តម **ញឹម វណ្ណដា**
- លោក **ឃឹម សារិទ្ធ** ជំនួយការឯកឧត្តម **មាង ជួន**
- លោក **សុខ ធីរៈ** ជំនួយការឯកឧត្តម **ចាន់ គិន**
- លោក **ម៉ុន ខេង** ជំនួយការលោកជំទាវ **ហួ ណួន**
- លោក **អ៊ុត ចាន់ឡុង** ជំនួយការឯកឧត្តម **ប៊ុល ណារ៉ាល់**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៣ សសរ

ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងតំបន់ប៉ៃលិន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ កែ កក្កដា ឆ្នាំ ១៩៩៤ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងតំបន់ប៉ៃលិន ដែលមានសមាសភាពដូចខាងក្រោម ÷

១ - ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ប្រធាន

២ - ឯកឧត្តម **ហូ សុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៣ - លោកឧត្តមសេនីយ៍ **ជា សារ៉េត** មេបញ្ជាការរងយោធភូមិភាគ ២ អនុប្រធាន

៤ - លោកឧត្តមសេនីយ៍ **អ៊ុក គីមលេខ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អនុប្រធាន

៥ - លោកឧត្តមសេនីយ៍ **ខឹម ជាសុខឿន** មេបញ្ជាការរងយោធភូមិភាគពិសេស អនុប្រធាន

៦ - លោកឧត្តមសេនីយ៍ **ចំរើន ជាតិ** អនុប្រធានយោធភូមិភាគទី ៥ អនុប្រធាន

៧ - លោកឧត្តមសេនីយ៍ **ហាច្យ យុទ្ធ** អនុប្រធានទី ១ នាយកដ្ឋានកណ្តាលសន្តិសុខ អនុប្រធាន

៨ - លោកឧត្តមសេនីយ៍ **ជា សារិន** នាយការិយាល័យទី ៣ អគ្គសេនាធិការ អនុប្រធាន

៩ - លោកឧត្តមសេនីយ៍ **ថ្វាំ មរណៈ** អនុប្រធាន

១០ - លោក **ឈាំ ទុំ** អភិបាលរងទី២ ខេត្តបាត់ដំបង អនុប្រធានប្រចាំការ សមាជិក

១១ - លោក **ផ្លាង ចន្ទ** អគ្គនាយករងរដ្ឋបាល សមាជិក

១២ - លោក **ជួន ខ្វា** ប្រធានមន្ទីរសាធារណការខេត្តបាត់ដំបង សមាជិក

១៣ - លោក **គុយ ដោក** នាយផ្នែកការិយាល័យទី ១ អគ្គសេនាធិការ សមាជិក

១៤ - លោក **ជឹម តៀយ** មេបញ្ជាការសឹករងតំបន់ប៉ៃលិន សមាជិក

១៥ - លោក **សុខ ចំរើន** អនុប្រធាននាយកដ្ឋាន នគរបាលការពារ សមាជិក

១៦ - លោក **ជួន ចោម** បញ្ជាការកងរាជអាវុធហត្ថតំបន់ប៉ៃលិន សមាជិក

១៧ - លោក **ទេព ទិចិត្រ** នាយរងការិយាល័យទី ៥ អគ្គសេនាធិការ សមាជិក

១៨ - លោក **អៅ គីមឈួន** ទីប្រឹក្សា ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៩ - លោក **ម៉ែន សិទ្ធី** អនុប្រធាននាយកដ្ឋានសុខាភិបាលក្រសួងមហាផ្ទៃ សមាជិក

២០ - លោក **ឈឹម នី** មន្ត្រីនាយកដ្ឋានរដ្ឋបាលទូទៅ សមាជិក

២១ - លោក **ផ្លាក់ ប៊ៀច** អនុប្រធានមន្ទីរសេដ្ឋកិច្ច ហិរញ្ញវត្ថុខេត្តបាត់ដំបង សមាជិក

២២ - លោក **ស ខេមខូ** អនុប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង សមាជិក

២៣ - លោក **សោម សារ៉ាអ៊ី** ប្រធានការិយាល័យទី ៣ រាជអាវុធហត្ថខេត្តតាកែវ សមាជិក

២៤ - លោក **ថ្លាក់ សន់** អភិបាលរងស្រុករតនមណ្ឌល សមាជិក

២៥ - លោក **ពិន ម៉ិត** ប្រធានការិយាល័យភូមិបាលស្រុករតនមណ្ឌល សមាជិក

២៦ - លោក **ព្រហ្ម សុខុន** ស្នងការរដ្ឋាននគរបាលខេត្ត បាត់ដំបង សមាជិក

២៧ - លោក **សំ គី** ស្នងការរដ្ឋាននគរបាលខេត្ត បាត់ដំបង សមាជិក

ប្រការ ២ : គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

- សហការ និងដឹកនាំបញ្ជាកងកម្លាំងប្រដាប់អាវុធ ដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់ក្នុងតំបន់ប៉ៃលិន ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលដែនដី និងទំរង់បែបបទសុំបង្កើតថ្នាក់រដ្ឋបាលប៉ៃលិន ។
- កសាងហេដ្ឋារចនាសម្ព័ន្ធ គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ ដោះស្រាយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ យកចិត្តទុកដាក់ដល់ការងារអប់រំ សង្គមកិច្ច សុខាភិបាល ថែរក្សាសម្បត្តិវប្បធម៌ជាតិ និង បរិដ្ឋានធម្មជាតិ ។
- បំពេញកិច្ចការផ្សេង ៗ ទៀតដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

ប្រការ ៣ : គណៈកម្មាធិការនេះមានសិទ្ធិ :

- លើកសំណើរៀបចំមន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

- បង្កើតអនុគណៈកម្មការនានាជាជំនួយការ ។
- សហការជាមួយអាជ្ញាធរខេត្តបាត់ដំបង ជ្រើសរើសមន្ត្រីជំនាញពីមន្ទីរនានានៅក្នុងខេត្ត ដើម្បីយកមកបំរើការងាររបស់គណៈកម្មាធិការ ។
- លើកគំរោងសកម្មភាពការងារ និង ថវិកាដើម្បីសុំការសំរេចពីរាជរដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ ។
- បែងចែកដីលំនៅដ្ឋានដល់ប្រជាពលរដ្ឋដែលទៅរស់នៅតំបន់ប៉ៃលិន ។

ប្រការ ៤ : គណៈបញ្ជាការសមរភូមិតំបន់ប៉ៃលិន និងគណៈកម្មាធិការនេះត្រូវសហការគ្នាអោយបានល្អ ដើម្បីបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

ប្រការ ៥ : គណៈកម្មាធិការនេះ មានត្រារបស់ខ្លួនដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ប្រការ ៦ : អនុញ្ញាតអោយគណៈកម្មាធិការនេះមានគណនីដោយឡែក សំរាប់បំរើសំណូមពរការងារ ។

ប្រការ ៧ : គណៈកម្មាធិការនេះត្រូវចំណុះផ្ទាល់ក្រសួងមហាផ្ទៃ និង បំពេញការងាររហូតដល់មានការប្រកាសជាផ្លូវការថ្នាក់រដ្ឋបាលប៉ៃលិន ។

ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តបាត់ដំបង និង ឯកឧត្តម អស់លោក ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៣១៨ ឧ.ព.ប្រ.ក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុន សុផល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២១៦៩៧ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ 2 CE0 ផ្លូវជ្រុនយូហាក់ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌ ចំការមន បើកដំណើរការរោងម៉ាស៊ីនបំរុង ផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០១ គ្រឿង ដែលមានកំលាំងសរុប ៤៥០ KVA នៅក្នុងតំបន់ បន្ទប់ភ្លើងលេខ ប.ត ០៩០ ដែលស្ថិតនៅផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ប្រការ ២ : លោក **អ៊ុន សុផល** ត្រូវអនុវត្តថ្លៃលក់ថាមពលអគ្គិសនីក្នុង 1kWh តាមរូបមន្ត : $\frac{(350\text{៛} \times H) + (700\text{៛} \times h)}{H+h}$ ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តខែបន្ទាប់ ។

H = ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ០៩០ ក្នុងខែមុន

h = ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛ = ថ្លៃលក់ថាមពលអគ្គិសនី ដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

700៛ = ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង

ប្រការ ៣ : ប្រកាសនេះមានតំលៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត ០៩០ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់បញ្ញតិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣១៩ ឧ.ព.ប្រ.ក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហុង ឈីវគង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២៨២២៤ ភ.ព ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ 90ABE0 ផ្លូវលេខ ១២៨ សង្កាត់មនោរម្យ ខ័ណ្ឌ ៧មករា បើកដំណើរការរោងម៉ាស៊ីនបំរុង ផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ០១គ្រឿង ដែលមានកម្លាំងសរុប ២០០ KVA នៅក្នុងតំបន់បន្ទប់ភ្លើង លេខ បត ១៩០ ដែលស្ថិតនៅផ្ទះលេខ90ABE0 ផ្លូវលេខ ១២៨ សង្កាត់មនោរម្យ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក ហុង ឈីវគង់ ត្រូវអនុវត្តថ្លៃលក់ថាមពលអគ្គិសនី ក្នុង 1KWH តាមរូបមន្ត : (៣៥០៛ ×H)+(៧០០ ៛ × h)ដោយស្រង់តួលេខខែមុនសំរាប់

H+h

អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ១៩០ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

៣៥០៛ ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

៧០០៛ ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតំលៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បនប.ត ១៩០នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវ

– បានឃើញ...

ដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ិត ប្រាំង

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៩៨/៩៦ ព.ម.ប្រ.ក

អនុញ្ញាតជូនលោក ញ៉ែម វ៉ាលី បើកអាជីវកម្មរោងពុម្ព

ឈ្មោះ « រណសិរ្ស ២ ធ្នូ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញ ព្រះរាជក្រមលេខ ន.ស-រ.ក.ម-១០.៩៦.១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតជូនដំណឹង របស់ក្រសួងពត៌មាន លេខ ១២២៤.៩៤ ព.ម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «រណសិរ្ស ២ ធ្នូ» របស់លោក ញ៉ែម - វ៉ាលី ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **សៀម ទ៉ាលី** ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៣៧៧ អ៊ី.អូ វិថីព្រះស៊ីសុវត្ថិ ក្រុមទី ៣ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « វណ្ណសិរ្ស ២ ធ្នូ » ទីតាំងស្ថិតនៅផ្ទះលេខ ៣៨៩ អ៊ីអូ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់សន្តិ សុខសណ្តាប់ធ្នាប់សង្គម និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ - សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៨៦

ប្រកាសលេខ ០៩៩/៩៦ ព.ម.ប្រ.ក

អនុញ្ញាតឱ្យព្រឹត្តិបត្រឈ្មោះ « ព្រឹត្តិបត្ររាជធានីភ្នំពេញ »

មន្ត្រីពត៌មានផ្សាយ

– បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី៤១

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីរបបសារពតិមាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រមលេខ ន.ស-រ.ក.ម-០៨៩៥-០៧ ចុះថ្ងៃ ទី ០១ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពផ្សាយព្រឹត្តិប័ត្រឈ្មោះ « ព្រឹត្តិប័ត្ររាជធានីភ្នំពេញ » របស់ លោក គង់ ម៉ូនីរិទ្ធ អនុប្រធានមន្ទីរពតិមានរាជធានីភ្នំពេញ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយព្រឹត្តិប័ត្រឈ្មោះ « ព្រឹត្តិប័ត្ររាជធានីភ្នំពេញ »បន្តចេញផ្សាយ ដោយមានលោក **គង់ ម៉ូនីរិទ្ធ** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ២៥អឺ.០ និង ៧អឺ០ ផ្លូវ១៤០ សង្កាត់មនោរម្យ រាជធានីភ្នំពេញ ។ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណប័ណ្ណ នៃព្រឹត្តិប័ត្ររបសខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃមកក្រសួងពតិមានដើម្បី រង់ចាំសេចក្តីសំរេចថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែក ផ្សាយ ត្រូវគោរពតាម គោលការណ៍ ក្រមសីលធម៌អ្នកសារពតិមាន និងឈរលើ ស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទ ត្រូវអនុវត្តអោយបានសមស្របតាម ទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ព្រឹត្តិប័ត្រចំនួន ០៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តី ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាម៉ីខ្លួន ត្រូវទទួលទោសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ - នាយកមណ្ឌលពតិមាន និងលោក

ចាងហ្វាងការផ្សាយ «ព្រឹត្តិប័ត្ររាជធានីភ្នំពេញ »ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១០០/៩៦ ព.ម.ប្រ.ក

អនុញ្ញាតឱ្យទស្សនាវដ្តីឈ្មោះ « សម្លេងសហគមន៍ »

បោះពុម្ពចែកផ្សាយ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី៤១
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រមលេខ ន.ស-រ.ក.ម-០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពផ្សាយទស្សានាវដ្តីឈ្មោះ«សម្លេងសហគមន៍» ចុះថ្ងៃទី ០១ កុម្ភៈ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ «សម្លេងសហគមន៍ »បោះពុម្ពចែកផ្សាយ ដោយមានលោក **ជាញ់ សុខា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ

៧២១ អឺ.០ ផ្លូវកម្ពុជាក្រោម ក្រុង ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណប័ណ្ណនៃទស្សនាវដ្តីរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ១០ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទ ត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ទស្សនាវដ្តីចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារ នៅ ក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តី ដូចមានចែងក្នុងប្រការ១ និងប្រការ ២ ខាងលើ សាម៉ីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ - នាយកមណ្ឌលពត៌មាន និងលោកចាងហ្វាងទស្សនាវដ្តី « សម្លេងសហគមន៍ » ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១០១/៩៦ ព.ម.ប្រ.ក

អនុញ្ញាតឱ្យទស្សនាវដ្តីឈ្មោះ « THE CAMBODIAN SCENE » បោះពុម្ពចែកផ្សាយ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី៤១

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រមលេខ ន.ស-រ.ក.ម-០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ « THE CAMBODIAN SCENE » ជាភាសាអង់គ្លេស និង ខ្មែរ ចុះថ្ងៃទី ១៨ ខែ ធ្នូ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ « THE CAMBODIAN SCENE » ជាភាសាអង់គ្លេស និងខ្មែរ បោះពុម្ពចែកផ្សាយដោយមានលោក **សុវណ្ណឌី យឹម** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៦១ ផ្លូវ ១៩២ សង្កាត់ទឹកល្អក់ ៣ ខ័ណ្ឌទួលគោក ក្រុង ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយ ក្នុងអត្តសញ្ញាណប័ណ្ណ នៃទស្សនាវដ្តីរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្ត អោយបានសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រម ទាំងស្នើប្រគល់ទស្សនាវដ្តី ចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តី ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ - នាយកមណ្ឌលពត៌មាន និងលោក ចាងហ្វាងទស្ស នាវដ្ដី « THE CAMBODIAN SCENE » ត្រូវអនុវត្តនូវ ប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

៣ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣៧១ អយក.ប្រក
ស្ដីពីការប្ដូរឈ្មោះអនុវិទ្យាល័យពាមរាំង ទៅជា
«អនុវិទ្យាល័យម្ចាស់ក្សត្រីយ៍ម៉ារីរណឫទ្ធិ »
ស្ថិតក្នុង ស្រុកឈើកដែក ខេត្ត កណ្ដាល
រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុ-

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃ គណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំនេះ ទូទៅ ។
- យោងលិខិតសំណើ របស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យពាមរាំងលេខ ៣៥/៩៥ អ.វិ.ព.រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩៥ ដោយមានយោបល់ ឯកភាពពីមន្ទីរអប់រំយុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យពាមរាំង បច្ចុប្បន្នទៅជា«អនុវិទ្យាល័យ ម្ចាស់ក្សត្រីយ៍ **នរោត្តម ម៉ារី រណឫទ្ធិ -ពាមរាំង** » ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធាន មន្ទីរអប់រំ យុវជននិងកីឡា ខេត្តកណ្តាល និងនាយកអនុវិទ្យាល័យ ម្ចាស់ក្សត្រីយ៍ ម៉ារី រណឫទ្ធិ -ពាម រាំង មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣៧២ អយក.ប្រក

ស្តីពីការបើក « អនុវិទ្យាល័យ បានយ » ក្នុង

ស្រុកព្រែកប្បាស ខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំនេះ ទូទៅ ។
- បានឃើញ សារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១ - កំរិត២ ។
- យោងលិខិតលេខ ៩៥០ អយក.ត ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់មន្ទីរអប់រំយុវជននិង កីឡា ខេត្តតាកែវ ដោយមានការឯកភាពពីអភិបាល ខេត្តតាកែវ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជននិងកីឡា ខេត្តតាកែវ បើក អនុវិទ្យាល័យ បានយ ជាផ្លូវការ នៅក្នុងឃុំអង្កាញ់ ស្រុកព្រែកប្បាស ខេត្តតាកែវ ចា[illegible] ឆ្នាំ សិក្សា ១៩៩៥ - ៩៦ នេះតទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិក ផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក - នាយករង នៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករង នៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ នាយកអនុវិទ្យាល័យ បាទយ មានភារកិច្ចរៀងៗខ្លួនអនុវត្ត ប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

គុណ ឡោះ

* * *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៣០ រៀល